ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែមេសា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែមេសា ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសត្រូវបានបញ្ចប់ដោយសម្រេចធ្វើការដាំដុះបានចំនួន ៥៩៧ ៥០៨ហ.ត ស្មើនឹង១៣០% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជីថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែមេសា ឆ្នាំ២០២០នេះ គឺបានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗ ឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែមេសា ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលបញ្ចប់ផ្នែកដាំដុះរដូវប្រាំងឆ្នាំ២០១៩-២០២០

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦០២ ៣៣២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៤ ២៦៦ហ.ត និងដោយគ្រឿងយន្តមានចំនួន ៥៩៨ ០៦៦ហ.ត តិចជាងឆ្នាំមុនចំនួន ៣០ ៥៧០ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៧៤ហ.ត តិចជាងឆ្នាំមុនចំនួន ៩៨ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៥៩៧ ៥០៨ហ.ត ស្មើនឹង១៣០% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត លើសឆ្នាំមុនចំនួន ១ ០២៥ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០

ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៥៩២ ១២៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ៦១៦ ២៥៣តោន។ ទិន្នផលគិតជាមធ្យម ៤,៤១៨តោន/ហ.ត។

#### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៩-២០២០

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៣៧ ៦២៦ហ.ត ស្មើនឹង១១៦,១២% នៃផែនការចំនួន ៣២ ៤០៣ហ.ត លើសឆ្នាំមុនចំនួន ២ ៣៦៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៩ ២៧៤ហ.ត ស្មើនឹង៧៤,៨៨% នៃផែនការចំនួន ១០៥ ៨៧៣ហ.ត តិចជាងឆ្នាំមុនចំនួន ១០ ៣៦៧ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

### ១.៤ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៦៩ ៣០៤តោន មានការកើនឡើងចំនួន ២៦ ៣៦២តោន (+៦១,៤%) ច្រើនជាងបរិមាណនាំចេញក្នុងខែមេសា ឆ្នាំ២០១៩ ចំនួន ៤២ ៩៤២តោន និងបាននាំចេញទៅកាន់ទិសដៅចំនួន ៥៤ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ (១២២ ០៩៤តោន) ប្រទេសបារាំងលំដាប់ទី២ (៣៤ ៥៧៤តោន) ប្រទេសហ្គាបុងលំដាប់ទី៣ (១៦ ៥១១តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (១៥ ០៩៧តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៥ (១៣ ៤៨៣តោន) ប្រទេសណេដឺឡែនលំដាប់ទី៦ (១៣ ៣៤៣តោន) ប្រទេសវៀតណាមលំដាប់ទី៧ (១២ ៥៦៤តោន) ប្រទេសអង់គ្លេសលំដាប់ទី៨ (៧ ៩៩៣តោន) ប្រទេសប៉ូឡូញលំដាប់ទី៩ (៦ ៤២៦តោន) និងប្រទេសអេស្ប៉ាញ ឈរលំដាប់ទី១០ (៦ ២៧៩តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៦៤ក្រុមហ៊ុន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ៨០១ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៥០ ០៦៦ហ.ត ស្មើនឹង៦២% និងផ្ទៃដីថែទាំចំនួន១៥៤ ៧៣៥ហ.ត ស្មើនឹង៣៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ១៨ ៩៦១តោន កើនឡើងចំនួន ៨ ១៣៧តោន ស្មើនឹង៧៥% ធៀបខែមុន និងកើនឡើងចំនួន ៤ ៥៤១តោន ស្មើនឹង៣១% ធៀបខែមេសា ឆ្នាំ២០១៩។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ១៨ ៦០៤តោន កើនចំនួន ៦ ៨៥៣តោន ស្មើនឹង៥៨% ធៀបខែមុន និងកើនឡើងចំនួន ៣ ៣២២តោន ស្មើនឹង២២% ធៀបខែមេសា ឆ្នាំ២០១៩។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យម គឺ ១ ១៩២ដុល្លារ/តោន ថយចុះចំនួន ២០៥ដុល្លារ/តោន ស្មើនឹង១៤,៦៧% ធៀបខែមុន និងថយចុះចំនួន ១៧៣ដុល្លារ/តោន ស្មើនឹង១៣% បើធៀបខែមេសា ឆ្នាំ២០១៩
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការ គឺទឹកជ័រ (DRC 100%) និងជ័រកក (DRC50%) គឺពុំមានការលក់ដោយសារសម្រាកចៀរជ័រ។

## ៣ ផ្នែករុក្ខាព្រៃឈើ

### ៣.១ ការងាររុក្ខាព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២០ ចំនួន ១០ផ្ទាំង សម្រាប់បន្តការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០ និងចុះប្រមូលព័ត៌មាននៅទីវាលជាក់ស្តែងតាមចំណុចនិយាមកាមួយចំនួនដែលបានធ្វើការចាត់ថ្នាក់រូបតាមរូបភាពផ្កាយរណប (LANDSAT8) ក្នុងកម្មវិធី ArcGIS ដែលមានភាពមិនច្បាស់លាស់ដើម្បីផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតជឿជាក់បានចំនួន ១៧០ចំណុច
- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់តំបន់សក្តានុពលព្រៃសហគមន៍ចំនួន ៣កន្លែង គឺសហគមន៍ព្រៃឈើភ្នំខ្ពប សហគមន៍ព្រៃឈើភ្នំនរាយណ៍ និងសហគមន៍ព្រៃឈើជ្រោះគគីរដែកមានផ្ទៃដីទំហំ ៥៤០,៥៥ហ.ត នៅក្នុងស្រុកឈូក និងស្រុកដងទង់ ខេត្តកំពត
- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៤គ្រឿង ជូនប្រជាពលរដ្ឋនៅក្នុងខេត្តបាត់ដំបង
- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់ មានឈើអារចំនួន ១០៥ម៣ និងជ័រទឹកចំនួន ១០០តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវ និងកំណត់តំបន់ព្រៃឈើដែលមានសក្តានុពលទេសចរណ៍ធម្មជាតិចំនួន ១លើកនៅសហគមន៍ព្រៃឈើក្បាលបីនៅភូមិក្បាលបី ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ
- បានចុះសិក្សាស្រាវជ្រាវ និងតាមដានវត្តមានសត្វព្រៃចំនួន ១លើក នៅតំបន់សហគមន៍វាលកន្សែង នៅឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ។ ក្រុមការងារបានកត់ត្រានូវប្រភេទថនិកសត្វចំនួន ៣៦ប្រភេទ បក្សីចំនួន ៦៥ប្រភេទ

និងឧរង្គសត្វចំនួន ៣៥ប្រភេទ ក្នុងនោះមានប្រភេទរងគ្រោះជិតផុតពូជបំផុតចំនួន ១ប្រភេទ ប្រភេទកំពុងរងគ្រោះជិតផុតពូជចំនួន ៤ប្រភេទ និងប្រភេទងាយរងគ្រោះចំនួន ១៤ប្រភេទ

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ២៨ច្បាប់ ក្នុងនោះ ២៧ច្បាប់សម្រាប់ការថែរក្សាសត្វក្រចៀកកាំ និង១ច្បាប់ទៀតសម្រាប់ការថែរក្សាសត្វជ្រូកព្រៃ។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- កសិដ្ឋានចំនួន ៧កន្លែង បានថែរក្សា និងបង្កាត់ពូជស្វាក្តាមសរុបចំនួន ៦២ ៥៨៦ក្បាល ក្នុងនោះ កូនកើតក្នុងខែចំនួន ៣ ៣៥០ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៩៥០ក្បាល និងដឹកជញ្ជូនឆ្លងទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសមានចំនួន ១ ០៨០ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៩០៩ក្បាល (បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៦ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១៤៩ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៣៩ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ១៣៦ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ១ ៨៣០ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃទំហំ ២,៤៥ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំចម្ការឈើសរុប ៩៣២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៨៩ហ.ត ឡូតិ៍បង្ហាញ កសិ-រុក្ខកម្មទំហំ ៤៩ហ.ត ចម្ការឈើដាំទំហំ ៧៥៤ហ.ត និងចម្ការរុក្ខទិវា ៩កក្កដា ទំហំ ៤០ហ.ត (ខេត្តកំពត កណ្តាល កំពង់ធំ និងខេត្តក្រចេះ)

- គម្រោងដាំឈើជាចម្ការថ្មីប្រចាំឆ្នាំ២០២០ លើផ្ទៃដីទំហំ ១៥២ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ស្ថិតនៅក្នុងខេត្តកំពង់ធំ បានឈូសឆាយសម្អាតដីទំហំ ១០ហ.ត

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ១៦១ ២៩៥ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ១៤០ ៦១៥ដើម និងថ្នាលបណ្តុះកូនឈើចំនួន ៦កន្លែង ក្នុងខេត្តចំនួន ៥រួមមាន៖ ខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្តាល ២កន្លែង ២០ ៦៨០ដើម

- បានប្រគេន ចែកចាយកូនឈើដល់ព្រះសង្ឃ ប្រជាពលរដ្ឋចំនួន ៩ ៨៤៤ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើទូទាំងប្រទេសចំនួន ៨ ៨៤៤ ដើម និងថ្នាលបណ្តុះកូនឈើចំនួន ៦ទីតាំងចំនួន ១ ០០០ ដើម។

### ៣.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១៦៦ករណី ដោយពិន័យអន្តរការណ៍ចំនួន ៧៧ករណី និងបញ្ជូនទៅតុលាការចំនួន ៨៩ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងចំនួន ១៨ម$^3$ ឈើអារសរុបចំនួន ២៩៦ម$^3$ (ចំនួន ១៤៩ករណី) ផ្ទៃដីព្រៃឈើកាប់រានទំហំ ៤៧ហ.ត នៅខេត្តកំពង់ឆ្នាំង៣ករណី ក្រចេះ២ករណី និងខេត្តព្រះវិហារ១ករណី វត្ថុតាងសត្វព្រៃបានចាប់ឃាត់ចំនួន ៤០៤ក្បាល និង២៥៨គ.ក្រ និងអនុផល ព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត។

### ៣.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ២កន្លែងនៅខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប

- បានបង្កើតឡធ្យូងប្រើប្រាស់វត្ថុធាតុដើមពីឈើអាកាស្យា និងឈើដាំផ្សេងទៀតចំនួន ១កន្លែង (ក្រុមហ៊ុន ស៊ែយុង គ្រេឌីង) និងរោងសិប្បកម្មអារកែច្នៃឈើចំនួន ១កន្លែង

- បានពន្យារសុពលភាពរោងម៉ាស៊ីនផលិតវីនៀរ និងឈើកែច្នៃចំនួន ១កន្លែង (ក្រុមហ៊ុន ខេ អាយ យូ ផ្លេនថេសិន (ខេមបូឌា)

- ក្រុមហ៊ុនចំនួន ៣បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសមានចំនួន ៣៥៩ម$^3$ និងជ័រទឹកចំនួន ២៥តោន

- ក្រុមហ៊ុនចំនួន ២បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ២០៩ម³

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ៣មានឈើកែច្នៃចំនួន ១៣០ម³ ប្រេងខ្យល់កាត់ជាកង់ៗចំនួន ១ ៥០០ស្ទែរ និងជ័រទឹកចំនួន ៤០តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ១មានបរិមាណឈើកែច្នៃ (Doussie) ចំនួន ១៦០ម³។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ២ ៤១៣ ៨៣៤ ៤៨៨រៀល និង២៣ ២៧៥,៣៨ ដុល្លារ។

## ៤ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។

### ៤.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** រាជធានី-ខេត្តចំនួន ២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៥ ៧៨៥លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៣១ករណី ក្នុងនោះឃាត់ចាប់ចំនួន ២ករណី។
- **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះផ្សព្វផ្សាយជំងឺផ្តាសាយបក្សីនៅខេត្តចំនួន ២ ដែលមានអ្នកចូលរួមសរុបចំនួន ៥៥នាក់ (ស្រី៣៣នាក់) ។
- **ការងារនីតិកម្ម និងវិវាទ**

- បានធ្វើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលប្រកាសរួមលេខ១០១៣ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានធ្វើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ កំពុងឆ្លងការពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៧ក្បាល។ ដោយឡែក ស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនត្រូវបានបិទទាំងស្រុងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ ដោយសារមានការឆ្លងរាលដាលនៃជំងឺប៉េស្តជ្រូកអាហ្វ្រិក។
- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១ ៧៥៥វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តសរុបរយៈពេល៤ខែបានចំនួន ១ ៥០០តោន ស្មើនឹង១២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ ថយចុះចំនួន ៨៧០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ២០ ៧៥០តោន សរុបរយៈពេល៤ខែចំនួន ៩០ ១០០តោន ស្មើនឹង២៦,១២% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ ថយចុះចំនួន ៩០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៣ ៨០៥តោន សរុបរយៈពេល៤ខែចំនួន ២១ ៣១៥តោន ស្មើនឹង ១៤,៧០% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៤៩៥តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៩ ៩៨០តោន សរុបរយៈពេល៤ខែចំនួន ៣៥ ៧៦០តោន ស្មើនឹង៣២,៥១% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ កើនឡើងចំនួន ៥១០តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២៥ ០៥៦តោន សរុបរយៈពេល៤ខែចំនួន ៧៦ ៩២២តោន ស្មើនឹង ២១,៣៧% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ កើនឡើងចំនួន ១២ ៨២០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៩ ៦៥០ក្បាល សរុបរយៈពេល៤ខែចំនួន ៤០ ៤០០ក្បាល ស្មើនឹង១៣,៤៧% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ កើនឡើងចំនួន ២០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២ ២០០ ០០០កូន សរុបរយៈពេល៤ខែចំនួន ៥០ ៧០០ ០០០កូន ស្មើនឹង ២១,១៣% នៃផែនការចំនួន ២៤០ ០០០ ០០០កូន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៧០០ ០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ១ ៤០០តោន សរុបរយៈពេល៤ខែចំនួន ១៩ ១៥០តោន ស្មើនឹង២៣,៣៥% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ ថយចុះចំនួន ១ ០០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ៤៣០តោន សរុបរយៈពេល៤ខែចំនួន ៤ ០៨០តោន ស្មើនឹង៤៥,៣៣% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ កើនឡើងចំនួន ៣០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៥ ០១០ ០០០លីត្រ សរុបរយៈពេល៤ខែចំនួន ១៧ ៣១០ ០០០លីត្រ ស្មើនឹង៣១,៤៧% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ កើនឡើងចំនួន ២១០ ០០០លីត្រ។

**៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល**

- សំណុំរឿងបទល្មើសជលផលមានចំនួន ២០២ករណី ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ ថយចុះចំនួន ៧៤ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៨២ករណី និងសមុទ្រចំនួន ២០ករណី។

**៥.៥ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់អនុវត្តសរុបរយៈពេល៤ខែបានចំនួន ១ ១៤០តោន ស្មើនឹង៧,៦០% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៩១០តោន

- ផលនេសាទកែច្នៃអនុវត្តសរុបរយៈពេល៤ខែបានចំនួន ២៣២តោន ស្មើនឹង៤,៦៤% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០១៩ ថយចុះចំនួន ១ ១៥៨តោន។

**៥.៦ ការប្រមូលថវិកា**

ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១៣៨ ៨៤១ ៦០០រៀល សរុបរយៈពេល៤ខែចំនួន ២៣១ ៩៩៧ ៦៨០រៀល ស្មើនឹង៧,៧៥% នៃផែនការចំនួន ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបខែមេសាឆ្នាំ២០១៩ ថយចុះចំនួន ១៣៦ ០៣២ ១៩២រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- បានទទួលពាក្យបណ្តឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាន
- បានស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៦១ករណី
- បានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ១លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៦០៤ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២២២ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២១៤ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៦៨ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៧០៩ច្បាប់

ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៣៧ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៨ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៨៦នាក់ (ស្រី១ ៤៣៧នាក់) ស្មើនឹង២៤,៤១% រួមមាន៖

  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៥នាក់ (ស្រី៨៣៣នាក់) ស្មើនឹង២៨,៥៧%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩១៧នាក់ (ស្រី៨២៥នាក់) ស្មើនឹង២៨,២៨%

- បានរៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៣នាក់ ក្នុងនោះ ដោយសុំលាឈប់ពីការងារចំនួន ២នាក់ និងមរណភាពចំនួន ១នាក់

- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៧នាក់ (ស្រី៣នាក់)

- បានរៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ១២នាក់ (ស្រី៦នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ១០នាក់ និងច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ២នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ៣នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៣នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១១៧នាក់ (ស្រី៣០នាក់) ក្នុងនោះ៖

  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ១១៣នាក់ (ស្រី៣០នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៤នាក់។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានរៀបចំរបាយការណ៍ស្តីពីស្ថានភាពនៃការគ្រប់គ្រង និងការផ្គត់ផ្គង់ផលិតផលកសិកម្ម (បន្លែ ត្រី សាច់) ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានរៀបចំប្រមូលផ្តុំឯកសារវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុក

- បានបញ្ចូលទិន្នន័យតាមប្រព័ន្ធ Database

- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃចន្ទ ពុធ និងសុក្រ តម្លៃលក់រាយម្តងក្នុងសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទូទាំង២៥

- បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលនៅទូទាំង២៥រាជធានី-ខេត្ត

- បានចុះពិនិត្យ និងបំពេញបន្ថែមការអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃថវិកាកម្មវិធី១លើកនៅខេត្តកំពង់ចាម។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានចូលរួមដេញថ្លៃលក់ជាសាធារណៈនូវទ្រព្យសម្បត្តិរដ្ឋចាស់ៗខូចទ្រុឌទ្រោមប្រើប្រាស់លែងកើតដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបចំនួន ៣ ៤៥១ ៧០៨ ៦២០រៀល

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធNRMIS សរុបចំនួន ២ ៣៦៩ ៥៥៧ ២២៥រៀល

- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ២ ៩៩៣ ០៣៨ ៩៨៦រៀល

- បានសម្របសម្រួលជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(FMIS) ចុះមកក្រសួង(នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ) ចំនួន ១លើក

- បានរៀបចំលិខិតសំណើសុំថវិកាបដិភាគចំនួន ២៧២ ៦៤០ដុល្លារអាមេរិក សម្រាប់ចំណាយប្រតិបត្តិការរយៈពេល៤ឆ្នាំ (២០២០-២០២៣) ក្នុងកម្មវិធីគ្រប់គ្រងធនធានទឹកនិងវិវឌ្ឍនាការកសិកម្មអេកូឡូស៊ីនៅកម្ពុជាដំហានទី១ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទាន

- បានរៀបចំលិខិតសំណើសុំផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីអនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (CAPFISH-Capture) ក្រោមជំនួយហិរញ្ញប្បទានរបស់សហភាពអឺរ៉ុប

- បានទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៣ក្រុមហ៊ុន

- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន

- បានចុះពិនិត្យ និងវាយតម្លៃការងាររៀបចំបណ្តុះកូនឈើសម្រាប់ចែកចាយកសិករ និងការងាររៀបចំសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្នាលបណ្តុះកូនឈើសម្រាប់អនុវត្តគម្រោងដាំឈើប្រចាំឆ្នាំ២០២០ របស់រដ្ឋបាលព្រៃឈើនៅតាមសួនបណ្តុះ និងថ្នាលបណ្តុះកូនឈើនីមួយៗក្នុងគម្រោងអនុវត្តផែនការឆ្នាំ២០២០

- បានចូលរួមប្រជុំ និងចុះពិនិត្យវាយតម្លៃទីតាំងដីដែលស្នើសុំកត់ត្រាបញ្ចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលជលផល។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានទទួលលិខិតពីស្ថាប័ន អង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តចំនួន ២០ច្បាប់ និងបញ្ជូនលិខិតចេញចំនួន ១៣ច្បាប់

- បានធ្វើវិចារណកម្មចំណាយថវិកាលើកទី២ លើគម្រោងចំណាយរដ្ឋទេយ្យបុរេប្រទាន

- បានធ្វើវិចារណកម្មចំណាយថវិកាលើកទី២ លើគម្រោងថវិកាឆ្នាំ២០២០

- បានធ្វើវិចារណកម្មចំណាយថវិកាលើកទី២ លើគម្រោងថវិកាលទ្ធកម្មសាធារណៈ

- ពុំបានចុះធ្វើសវនកម្មតាមផែនការសកម្មភាព។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ពុំមានការទទួលជួបភ្ញៀវអន្តរជាតិរបស់ថ្នាក់ដឹកនាំ

- ពុំមានការចូលរួមកិច្ចប្រជុំ ទិវា ទស្សនកិច្ច និងសន្និសីទក្រៅប្រទេសរបស់ថ្នាក់ដឹកនាំ

- ពុំមានការចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្រៅប្រទេស

- បានកំពុងត្រៀមរៀបចំ និងប្រារព្ធទិវាពិភពលោកដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដីឆ្នាំ២០២០ ដែលនឹងប្រព្រឹត្តនៅថ្ងៃទី១៧ មិថុនា ឆ្នាំ២០២០ នៅខេត្តព្រះវិហារ

- បានរៀបចំករណីសំណើសុំគោលការណ៍អនុញ្ញាតចុះហត្ថលេខាលើកិច្ចសហកិច្ចព្រមព្រៀងអនុវត្តគម្រោងរបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ដើម្បីអនុវត្តគម្រោងការគ្រប់គ្រងស្រះសហគមន៍ជម្រកត្រី និងវារីវប្បកម្មប្រកបដោយនិរន្តរភាព

- បានរៀបចំករណីសំណើសុំគោលការណ៍អនុញ្ញាតចុះហត្ថលេខាលើកិច្ចសហកិច្ចព្រមព្រៀងអនុវត្តគម្រោងរបស់វិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍ (IRD) ស្តីពីការសហការបច្ចេកទេស និងវិទ្យាសាស្ត្រ។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជីកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៧ក្រុមហ៊ុន សរុបចំនួន ២១១មុខ

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៦ក្រុមហ៊ុន

- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ១ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៦ក្រុមហ៊ុន សរុបចំនួន ៥៧សំណាក។

### ១៣.៣ ការងារអនុវត្តច្បាប់

- បានធ្វើប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មរបស់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២ក្រុមហ៊ុន

- បានធ្វើការពិន័យអន្តរការណ៍ចំពោះក្រុមហ៊ុនពុំបានប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១ក្រុមហ៊ុន ស្មើនឹង១ករណី។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានបញ្ចូលតំណភ្ជាប់គេហទំព័ររបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងគេហទំព័រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១

- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលការប្រើប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៥គឺ ខេត្តព្រះវិហារ ក្រចេះ សៀមរាប កណ្តាល និងខេត្តស្វាយរៀង។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បាននិងកំពុងបន្តសហការអនុវត្តគម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

- បានប្រជុំណែនាំពីវិធីសាស្ត្រប្រមូលទិន្នន័យវិភាគសេដ្ឋកិច្ចគ្រួសារកសិករនៅខេត្តបាត់ដំបងមានអ្នកចូលរួមចំនួន ២០នាក់

- បានចុះទៅថត Video បទយកការណ៍ស្តីពីការចងក្រងបណ្តុំបន្លែសុវត្ថិភាពភ្ជាប់ទៅនឹងទីផ្សារខេត្តកណ្តាល និងធ្វើការផ្សព្វផ្សាយក្នុងកម្មវិធីនាទីកសិកម្មប្រចាំសប្តាហ៍

- បានចុះផលិតនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ គឺ បណ្តុំកសិករចិញ្ចឹមមាន់តាមតម្រូវការទីផ្សារ និងបណ្តុំកសិករដាំដំណាំខ្ទឹមស្លឹកនៅខេត្តកំពង់ឆ្នាំង

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ ក្នុងនោះ បច្ចេកទេសដាំដំណាំស្ពៃខៀវ ដាំដំណាំប៉េងប៉ោះ ដាំដំណាំផ្ទី ដាំដំណាំស្ពៃចង្កឹះ វិធានជីវសុវត្ថិភាពលើបច្ចេកទេសចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ និងបច្ចេកទេសការចិញ្ចឹមកង្កែបក្នុងអាង។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានរៀបចំសម្របសម្រួលក្នុងការចុះកិច្ចសន្យាទិញលក់ផលិតផលស្វាយចន្ទីរវាងក្រុមកសិករដាំស្វាយចន្ទីជាមួយសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទី ជ័យ សំបូរ នៅឃុំជ័យអារក្ស ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

- បានចុះពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពនៃការអភិវឌ្ឍដំណាំស្ពូត្ររបស់ក្រុមហ៊ុន ឆាយណាប្រ៊ូតខស នៅស្រុករវាង ខេត្តព្រះវិហារ

- បានចុះពិនិត្យសកម្មភាព និងការកែច្នៃគ្រាប់ស្វាយចន្ទីរបស់ក្រុមហ៊ុន សានតាណាប្រ៊ូប្រូដាក នៅឃុំរម្យណីស្រុករវាង ខេត្តព្រះវិហារ

- បានចុះពិនិត្យសកម្មភាព និងការកែច្នៃគ្រាប់ស្វាយចន្ទីរបស់សិប្បកម្មកែច្នៃស្វាយចន្ទី ជ័យ សំបូរ នៅឃុំជ័យអារក្ស ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

- បានរៀបចំកិច្ចប្រជុំពិភាក្សាលើការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចូលរួមប្រជុំក្រុមប្រឹក្សាភិបាលលើកទី២ អាណត្តិឆ្នាំ២០២០-២០២៣ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បានប្រជុំផ្សព្វផ្សាយសេចក្តីណែនាំលេខ១២២ សណន.កសក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការចាត់វិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ (Covid-19) និងផ្សព្វផ្សាយវិធានការនានារបស់រាជរដ្ឋាភិបាលកម្ពុជា

- បានចុះប្រមូលទិន្នន័យពិសោធន៍នៅក្នុងស្រែពិសោធន៍របស់វិទ្យាស្ថាន ស្រែកសិករនានាក្នុងរាជធានី និងតាមបណ្តាខេត្តគោលដៅមួយចំនួន

- បានបន្តបញ្ចូលទិន្នន័យវិភាគលទ្ធផលពិសោធន៍ជាបណ្ដើរៗនិងបន្តចងក្រងកាតាឡុកពូជម្ទេសនិងក្រសាំងស្រូវ។

### ១៧.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានត្រួតពិនិត្យការបំពាក់សម្ភារលើដើមកៅស៊ូពិសោធន៍ និងសម្ភារប្រមូលទិន្នន័យ
- បានស្រង់ទិន្នន័យជ័រកៅស៊ូឡូត៍ពិសោធន៍ក្លូន IRAA01 IRAA10 និង SSCT01
- បានវាស់ទំហំដើមកៅស៊ូឡូត៍ពិសោធន៍ចំនួន ៣ឡូត៍ គឺ IRAA05 IRAA10 និង SSCT01
- បានស្រង់ទិន្នន័យទឹកជ័រលើចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ (d4) ចំនួន ៩ចម្ការពិសោធន៍ ប្រព័ន្ធចង្វាក់ចៀរបង្វិល (d3 d4 d5 d6) ចំនួន ២ចម្ការពិសោធន៍
- បានរៀបចំថ្នាំរំញោច Ethephon ដើម្បីលាបលើបច្ច័យពិសោធន៍តាមពិធីពិសោធន៍
- បានត្រួតពិនិត្យតាមដានការចៀរជ័រ និងប្រមូលផលជ័រគ្រប់ចម្ការពិសោធន៍នីមួយៗ
- បានវាស់ទំហំដើមសម្រាប់បើកមុខចៀរថ្មី និងរៀបចំសម្ភារបំពាក់ដើម
- បានថែទាំឡូត៍កៅស៊ូចៀរជ័រដូចជាលាបថ្នាំរំញោច និងលាបខ្លាញ់គោលើដើមកៅស៊ូចៀរជ័រ។

### ១៧.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- បានដាក់ឱ្យនិស្សិតទាំងអស់ចូលវិស្សមកាលតូចមុនពេលកំណត់
- បានយកចិត្តទុកដាក់ផ្សព្វផ្សាយ និងផ្គត់ផ្គង់សម្ភារអនាម័យជូនគ្រប់អង្គភាព និងមហាវិទ្យាល័យដើម្បីអនុវត្តតាមវិធានការការពាររបស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់មហាវិទ្យាល័យទាំងអស់បានត្រៀមរៀបចំឯកសារបង្រៀន និងកម្មវិធីបង្រៀនតាម Online ជូនដល់និស្សិត
- តាមមហាវិទ្យាល័យនីមួយៗបានស្រង់ទិន្នន័យនិស្សិតមាន Computer និងទូរស័ព្ទទំនើបដែលអានទទួលការបង្រៀននិងរៀនតាម Online ដោយរកឃើញនិស្សិតប្រមាណ ៦៥% អាចសិក្សាតាម Online បាន
- បានបើកវគ្គបណ្ដុះបណ្ដាលជំនាញទន់ និងBusiness Management ដល់និស្សិតកំពុងហាត់ការនៅរោងជាងឡាវ៉ាណូ តាមប្រព័ន្ធ Online។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ១ ០៨៨នាក់ (ស្រី៤៥៤នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី
- បានដំណើរការបង្រៀននិស្សិតគ្រប់ជំនាញពីឆ្នាំទី១ដល់ឆ្នាំទី៤ ប្រកបដោយភាពរលូន
- បានពិនិត្យ និងកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ បរិញ្ញា និងបរិញ្ញារងបន្ទាប់ពីទទួលកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់គ្រប់ជំនាញ
- បានរៀបចំកិច្ចប្រជុំគ្រប់ដេប៉ាតឺម៉ង់ចំនួន ១៣ ដោយលើកយកកម្មវិធីសិក្សាថ្នាក់បរិញ្ញា និងបរិញ្ញារង ដើម្បីពិនិត្យនិងកែលម្អគម្រោងមុខវិជ្ជានីមួយៗចំនួន ១៣លើក
- បានចូលរួមការតាំងពិព័រណ៍កសិកម្ម និងបច្ចេកវិទ្យាលើកទី៨ នៅសាកលវិទ្យាល័យ Rajamangala ប្រទេសថៃ ១លើក មានថ្នាក់ដឹកនាំ និងមន្ត្រីចំនួន ៥នាក់
- បានទៅទស្សនកិច្ចសិក្សាកសិដ្ឋានចិញ្ចឹមគោយកទឹកដោះក្នុងឱទ្យាន តេជោសែន ឫស្សីត្រើប ខេត្តព្រះវិហារ ចំនួន ១លើក
- បន្តសហការជាមួយ Vitrosyste ក្រុមហ៊ុនប្រទេសកូរ៉េ ជំរុញការស្រាវជ្រាវផ្នែកជាលិកាវប្បកម្ម
- បន្តសហការជាមួយ Cambodia-Japan Research Center for Agriculture របស់វិទ្យាស្ថានជាតិជំរុញការស្រាវជ្រាវលើដំណាំចេកអំបូងពណ៌លឿងរបស់ជប៉ុនក្នុងផ្ទះសំណាញ់
- បន្តសហការជាមួយក្រុមហ៊ុនចិនពិសោធន៍លើការចិញ្ចឹមត្រីបបែល
- បានដឹកនាំនិស្សិតដាំបន្លែពិសោធន៍មានដូចជា ស្ពៃក្តោប ស្ពៃចង្កឹះ ត្រសក់ និងពោតដំណើប។

### ១៧.៥ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៧១៩នាក់ (ស្រី២៨៤នាក់) លើជំនាញវិទ្យាសាស្ត្រ

កសិកម្ម កសិក្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- បានរៀបចំសាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្ដោប និងស្រូវនៅខេត្តកំពង់ចាម
- បានរៀបចំពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ទឹកលើអាងចិញ្ចឹមត្រីក្នុងកន្លែងពិសោធន៍ជលផលរបស់សាលា
- បានពិសោធន៍ប្រៀបធៀបការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម
- បានបន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ដង្កូវនាងព្រៃ
- បានសហការជាមួយលោកសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យជាតិកាង វ៉ុន ចុះធ្វើការស្រាវជ្រាវប្រភេទរុក្ខជាតិនៅកម្ពុជា និងចម្រាញ់ប្រេងរុក្ខជាតិចេញពីម្រេចបង្កើតបានជាទឹកអប់
- បានចូលរួមបណ្ដុះបណ្ដាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ប៉េងប៉ោះ ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

## III-សេចក្ដីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសបានបញ្ចប់ ដោយសម្រេចបានចំនួន ៥៩៧ ៥០៨ហ.ត ស្មើនឹង១៣០% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្ដែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្ដាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្ដូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកជាំនុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០ ដែលនឹងឈានចូលមកដល់នាពេលដ៏ខ្លីខាងមុខនេះ
- បន្តធ្វើការពិនិត្យសន្និធិស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តវិធានការបន្ទាន់ដើម្បីដោះស្រាយបញ្ហានៃការធ្លាក់ចុះថ្លៃផលិតផលផ្លែស្វាយ

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មនិងបសុព្យាបាល

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- បន្តអនុវត្តការបង្កាត់ពូជជ្រូកដោយសិប្បនិម្មិត។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កធ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងទំនាក់ទំនងទ្វេភាគី និងពហុភាគីសម្រាប់ការបណ្តុះ-បណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជីកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**